www.kidworship.kr

# ចំណងជើង៖ កំណើតរបស់ព្រះគ្រិស្ត



10Page

**Narration** យូរណាស់មកហើយមានភូមិតូចមួយ នៅក្នុងស្រុកណាសារ៉ែត ដែលគេបានហៅថាភូមិ
បេថ្លេហិម។ ប្រជាជននៅក្នុងភូមិនោះពួកគេមានជីវភាពក្រីក្រណាស់។ ក្នុងនោះដែរ
មានស្ត្រីព្រហ្មចារីម្នាក់នាងមានឈ្មោះ ម៉ារី
នាងបានភ្ជាប់ពាក្យជាមួយនឹងជាងឈើម្នាក់ដែលជាមនុស្សសុចរិតគាត់មានឈ្មោះ
យ៉ូសែប។ នៅក្នុងពេលនោះការអនុវត្តន៏
និងការអនុម័តច្បាប់គឺសម្រេចឡើងដោយព្រះបាទហេរ៉ូដ
ការនេះបានធ្វើឲ្យប្រជានជនរបស់ប្រទេសជិតខាងហូរចូលមករស់នៅក្នុងប្រទេសខ្លួន
នាំឲ្យការរស់នៅរបស់ប្រជាជនអ៊ីស្រាអ៊ែលរងនូវភាពឈឺចាប់ជាខ្លាំង
ប៉ុន្តែពួកគេនៅតែមានជំនឿជឿលើព្រះជាម្ចាស់
ដែលទ្រង់បានសន្យាក្នុងរយៈពេលជាយូរណាស់មកហើយ។ អឺ

**ប្រជាជន** នៅថ្ងៃណាមួយ យើងនឹងមានទារកចាប់កំណើតឡើង ហើយផ្តល់ឲ្យយើងនូវសេរីភាព!
ទ្រង់នឹងយាងមកសង្គ្រោះពួកយើង។

---



11Page

**Narration** ក្នុងរាត្រីមួយដែលនាងម៉ារីកំពុងតែគេងលក់ ទេវតាកាប្រីយ៉ែល
បានលេចមកនៅចំពោះមុខនាង។

**កាប្រ៊ីយ៉ែល** “ម៉ារីកុំខ្លាចអី ព្រះបានប្រទានពរដល់អ្នកហើយ
ទ្រង់ពិតជាសប្បុរសណាស់ទៅកាន់អ្នក។ អ្នកនឹងមានគតិដោយព្រះវិញ្ញាណបរិសុទ្ធ
ហើយប្រសូតបានបុត្រាមួយអ្នកត្រូវថ្វាយព្រះនាមបុត្រានោះថា “ យេស៊ូ” ។
ព្រះនឹងប្រទានឲ្យទ្រង់គ្រងរាជ្យបល្ល័ង្ករបស់ព្រះបាទដេវីឌរហូតតទៅ។

**មារី** “ខ្ញុំមិនទាន់រៀបការផង តើឲ្យខ្ញុំមានបុត្រដូចម្តេចទៅ” ?

**កាប្រ៊ីយ៉ែល** “ទារកនេះ មិនមែនកើតឡើងដោយចំណង់នៃមនុស្សទេ
ប៉ុន្តែកើតឡើងដោយអំណាចចេស្តារបស់ព្រះជាម្ចាស់វិញ
ទ្រង់នឹងក្លាយទៅជាបុត្ររបស់ព្រះជាម្ចាស់”។

**Narration** ម៉ារីពិតជាមានភាពភ័យខ្លាច ប៉ុន្តែនាងមានភាពជឿជាក់ និងស្តាប់បង្គាប់ព្រះ។

---



12Page

**ម៉ារី** “ព្រះជាម្ចាស់ខ្ញុំគឺជាអ្នកបំរើទ្រង់
ដូច្នេះសូមឲ្យសម្រេចតាមបំណងព្រះហឬទ័យរបស់ទ្រង់ចុះ”។

**Narration** នៅពេលនោះវាពិតជាគួរឲ្យភ័យខ្លាចខ្លាំងណាស់ ព្រោះស្ត្រីម្នាក់បានមានផ្ទៃពោះ
ដោយពុំទាន់បានរៀបការ។ នាងអាចនឹងត្រូវគេចោលនឹងដុំថ្មរហូតដល់ស្លាប់ព្រោះវាគឺ
ជាច្បាប់ ។ម្យ៉ាងទៀតនាងត្រូវប្រឈមមុខជាមួយ
យ៉ូសែបដែលត្រូវជាគូរដណ្តឹងរបស់នាង
គាត់អាចនឹងបោះបង់ចោលដោយមិនរៀបការជាមួយនាង។

ទោះបីត្រូវជួបនឹងភាពភ័យខ្លាចដូច្នេះក៏ដោយ
ប៉ុន្តែម៉ារីនាងបានជឿជាក់ចំពោះព្រះជាម្ចាស់និងស្តាប់បង្គាប់ទ្រង់
ព្រមទាំងអរព្រះគុណនិងសរសើរតម្កើងទ្រង់ផង។


13Page

យ៉ូសបែ "អ៊ំា តើរឿងនេះអាចកើតឡើងដូចម្តេចទៅ?
តើត្រូវរៀបការយ៉ាងម៉េចទៅ.........តើនាងអាចនឹងមានគតិដូចម្តេចទៅ
បើនាងមិនទាន់នឹងរៀបការជាមួយនឹងខ្ញុំផងនោះ? វាពិតជាមានការឈឺចាប់ខ្លាំងណាស់
ហ៊ឹម.......

Narration យ៉ូសែប គឺជាអ្នកដែលបានភ្ជាប់ពាក្យ ក្នុងការរៀបការជាមួយនឹងម៉ារី។
គាត់គឺជាមនុស្សល្អ ហើយសុចរិតម្នាក់
ប៉ុន្តែដំណឹងដែលថាម៉ារីមានគតិគឺជារឿងមួយដែលគួរឲ្យភ្ញាក់ផ្អើលណាស់សំរាប់គាត់។
យ៉ូសែបបានសម្រេចចិត្តថា គាត់មិនអាចរៀបការជាមួយនឹងម៉ារីទេ
ប៉ុន្តែនៅថ្ងៃបន្ទាប់ទេវតា

ទេវតា "យ៉ូសែប! ជាពូជរបស់ដេវីឌអើយ! កុំខ្លាចនឹងយកនាងម៉ារីធ្វើជាប្រពន្ធឡើយ
ដ្បិតបុត្រដែលបានចាប់កំណើតនៅក្នុងផ្ទៃរបស់នាងកើតចេញពីព្រះវិញ្ញាណបរិសុទ្ធទេ។
នាងនឹងប្រសូត្របានបុត្រាមួយ ហើយអ្នកត្រូវថ្វាយព្រះនាមបុត្រានោះថា "យេស៊ូ"
ពីព្រោះទ្រង់នឹងសង្គ្រោះរាស្ត្រទ្រង់ឲ្យរួចពីបាប។

យ៉ូសែប "អ៊ំា! ខ្ញុំយល់ហើយ"។


14Page

Narration បន្ទាប់ពីយ៉ូសែបបានស្តាប់ពាក្យរបស់ទេវតាមានបន្ទូលរួចហើយ។
គាត់ក៏បានរៀបការជាមួយនឹងម៉ារីដូចជាអ្វីដែលគាត់បានសន្យា។ ប៉ុន្មានខែក្រោយមក
យ៉ូសែបបាននាំម៉ារីដែលនាងកំពុងមានគតិ ធ្វើដំណើរទៅឯស្រុកកំណើតគឺនៅភូមិ
បេថ្លេហិម ពីព្រោះព្រះចៅក្រុងរ៉ូមបានបញ្ជាឲ្យមនុស្សគ្រប់គ្នា
បានត្រឡប់ទៅឯស្រុកកំណើតរបស់ពួកគេរៀងខ្លួន ដើម្បីធ្វើការជំរឿន។
ការធ្វើដំណើររបស់ពួកគេមានភាពយឺតយ៉ាវ ដូច្នេះ ម៉ារីនិងយ៉ូសែប
ពួកគេមិនអាចរកកន្លែងសំរាប់ស្នាក់នៅបានទេ
ព្រោះទីនោះមានមនុស្សច្រើនកុះករខ្លាំងណាស់។


15Page

យ៉ូសែប "តើអ្នកមានបន្ទប់ទំនេរទេ? ប្រពន្ធរបស់ខ្ញុំនាងជិតសំរាលហើយ
ខ្ញុំសូមត្រឹមតែបន្ទប់តូចមួយក៏បានដែរ"។

Narration អ្នកទាំងពីរមិនអាចរកកន្លែង សំរាប់ស្នាក់នៅយប់នោះបានទេ។
នៅចុងក្រោយពួកគេក៏បានសំរាកនៅកន្លែងដែលពួកគេអាចរកទៅបាន
នោះគឺនៅក្នុងក្រោលសេះ។ នៅវេលាយប់នោះទារក យេស៊ូក៏បានចាប់កំណើត ។
ទ្រង់គឺជាព្រះគ្រិស្ត ជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ ទ្រង់នឹងសង្គ្រោះរាស្ត្រ
ទ្រង់ឲ្យរួចពីបាប។